ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
លេខ : ០០៧/ប្រ.ក
២០០៥

រាជធានីភ្នំពេញ, ថ្ងៃទី៣១.ខែមករា.ឆ្នាំ២០០៥

# ប្រកាស

## ស្តីពីការចេញបណ្ណ និងផ្លាកលេខសំគាល់យានជំនិះ ក្នុងកងយោធពលខេមរភូមិន្ទ

*****

## សមាហរដ្ឋមន្ត្រីក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារៈកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការចេញផ្លាកលេខសំគាល់យានជំនិះ
- បានឃើញសេចក្តីសំរេចលេខ ០៤២/០៤ ស.ស.រ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការចេញប័ណ្ណអាវុធខ្លី ផ្លាកលេខសំគាល់សំភារៈសឹក ប័ណ្ណបើកបរ ប័ណ្ណសំគាល់ និងផ្លាកលេខយានយន្តគ្រប់ប្រភេទរបស់ក្រសួងការពារជាតិ ។

- ដើម្បីធានាដល់ការគ្រប់គ្រងយានជំនិះគ្រប់ប្រភេទក្នុងកងយោធពលខេមរភូមិន្ទ អោយមានសណ្តាប់ធ្នាប់របៀបរៀបរយនិងការប្រើប្រាស់ផ្លាកលេខចរាចរបានត្រឹមត្រូវតាមច្បាប់កំណត់ ។

## សម្រេច

### ប្រការ ១ : កំណត់ទូទៅ

១.១- ត្រូវបានផ្លាស់ប្តូរប័ណ្ណសំគាល់យានយន្ត និងផ្លាកលេខចរាចររបស់កងយោធពលខេមរភូមិន្ទ ដែលបានចេញអោយប្រើប្រាស់កន្លងមក ហើយប្រើប្រាស់ប័ណ្ណសំគាល់យានយន្ត និងផ្លាកលេខចរាចរថ្មី ។

១.២- យានយន្តគ្រប់ប្រភេទ ដែលត្រូវបានផ្តល់ប័ណ្ណសំគាល់ និងផ្លាកលេខចរាចរ គឺយានយន្ត ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយត្រូវបានចុះបញ្ជីសារពើភ័ណ្ឌ ដូចជាយានយន្តដែលរដ្ឋបំពាក់ អំណោយពីគ្រប់មជ្ឈដ្ឋាន ជំនួយបរទេស និងរបស់ក្រុមបេសកកម្មយោធាបរទេស ដែលប្រចាំរយៈពេលយូរ ។

១.៣- យានយន្តដែលត្រូវបានផ្តល់ប័ណ្ណសំគាល់ និងប្រើប្រាស់ផ្លាកលេខចរាចរ របស់កងយោធពលខេមរភូមិន្ទ ត្រូវបានកំណត់ប្រភេទ ដូចខាងក្រោម :

- ប្រភេទទី ១ : ទោចក្រយានយន្ត ត្រីចក្រយានយន្ត
- ប្រភេទទី ២ : រថយន្តតូច
- ប្រភេទទី ៣ : រថយន្តដឹកជញ្ជូនធុនស្រាល និងធុនធ្ងន់
- ប្រភេទទី ៤ : យានយន្តឧបករណ៍
- ប្រភេទទី ៥ : ក្បាលរថយន្តសណ្តោង . រ៉ឺម៉ក . សឺមីរ៉ឺម៉ក
- ប្រភេទទី ៦ : គ្រឿងយន្តវិស្វកម្ម
- ប្រភេទទី ៧ : គ្រឿងយន្តកសិកម្ម

### ប្រការ ២ : រូបភាព ផ្លាកលេខចរាចរ និងប័ណ្ណសំគាល់យានយន្ត

២.១- ផ្លាកលេខចរាចរ មានសរសេរជាអក្សរខ្មែរ អក្សរឡាតាំង លេខកូដសំគាល់ស្ថាប័នកងឯកភាព និងលេខកូដសំគាល់យានយន្តពណ៌ស ផ្ទៃពណ៌ខៀវខាងលើ ពណ៌ក្រហមខាងក្រោម ។

២.២- ប័ណ្ណសំគាល់យានយន្ត មានសរសេរលេខចរាចរម្ខាង និងម្ខាងទៀតមានសរសេរភិនភាគយានយន្ត ។

២.៣- ចំពោះលេខកូដសំគាល់ស្ថាប័នកងឯកភាព ប្រភេទយានជំនិះ និងលេខកូដចរាចរ អក្សរមានសរសេរនៅលើផ្លាកលេខសំគាល់យានជំនិះ ។

២.៤- យានយន្តរបស់កងយោធពលខេមរភូមិន្ទ ជាមធ្យោបាយដឹកជញ្ជូន អូសសណ្តោងសំភារៈយោធា ឬដឹកជញ្ជូនកងទ័ព ត្រូវមានសញ្ញាសំគាល់អង្គភាព លាបពណ៌គ្រែអ៊ី និងពណ៌ពិសេសផ្សេងៗទៀត ត្រូវបានកំណត់ដោយក្រសួងការពារជាតិ ។

**ប្រការ ៣ : លក្ខខណ្ឌប្រើប្រាស់**

៣.១- អនុញ្ញាតអោយប្រើប្រាស់ប័ណ្ណសំគាល់ ផ្លាកលេខចរាចរ ចំពោះតែយានយន្តដូចដែលបានកំណត់ក្នុងប្រការ.១ ។

៣.២- គ្រប់ស្ថាប័នកងឯកភាពត្រូវបំពេញបែបបទ ដើម្បីស្នើសុំប័ណ្ណសំគាល់យានយន្ត និងផ្លាកលេខចរាចរថ្មី តាមឋានានុក្រម និងតាមការណែនាំរបស់សមត្ថកិច្ចជំនាញទទួលបន្ទុក ដោយមានភ្ជាប់មកជាមួយនូវបញ្ជីរៀបរាប់លំអិតអំពីបរិមាណ គុណភាព និងប្រភពបំពាក់អោយបានច្បាស់លាស់ ។

៣.៣- គ្រប់មធ្យោបាយយានយន្តត្រូវពាក់ផ្លាកលេខអោយបានត្រឹមត្រូវនៅផ្នែកខាងមុខ និងផ្នែកខាងក្រោយយានយន្ត ។ ចំពោះយានយន្តដែលមានលក្ខណៈពិសេស ត្រូវពាក់ផ្លាកលេខនៅទីកន្លែងមួយជាក់លាក់ ដែលងាយស្រួលក្នុងការពិនិត្យ ។ មិនត្រូវធ្វើការឆ្លៃប្រឌិត តុបតែងបន្ថែមលើផ្លាកលេខធ្វើអោយខុសពីលក្ខណៈដើម ដែលច្បាប់បានកំណត់ ។

៣.៤- ការចេញប័ណ្ណ និងផ្លាកលេខសំគាល់យានយន្តអាចធ្វើទៅបាន លុះត្រាតែយានយន្តទាំងនោះបានបំពេញកាតព្វកិច្ចបង់ពន្ធនាំចូលតាមច្បាប់កំណត់របស់រដ្ឋ និងមានលក្ខណៈដូចចែងក្នុងប្រការ ១ ។

៣.៥- ចំពោះរថយន្តដែលខូចខាតមិនអាចប្រើប្រាស់បាន ដែលស្ថិតនៅក្នុងបញ្ជីគ្រប់គ្រង និងពុំទាន់មានសេចក្តីសំរេចផ្តាច់លើកាត់ចេញពីបញ្ជីគ្រប់គ្រង គឺត្រូវបានរក្សាទុកក្នុងបញ្ជី និងបញ្ចូលក្នុងស្ថិតិ ដែលត្រូវស្នើសុំប័ណ្ណសំគាល់យានយន្ត និងផ្លាកលេខចរាចរថ្មី រហូតដល់ពេលមានសេចក្តីសំរេចពីក្រសួងការពារជាតិ ។

- ចំពោះយានយន្តដែលធ្វើការផ្លាស់ប្តូរម៉ាស៊ីន ឬតួយានយន្ត ឬធ្វើអោយបាត់ប័ណ្ណសំគាល់ផ្លាកលេខចរាចរថ្មីនេះ ត្រូវធ្វើបែបបទដើម្បីសុំកែសំរួល ប័ណ្ណសំគាល់ ផ្លាកលេខចរាចរថ្មីទៀត សំរាប់ប្រើប្រាស់អោយត្រឹមត្រូវតាមស្ថានភាពជាក់ស្តែងរបស់យានយន្ត ។

**ប្រការ ៤ : សមត្ថកិច្ចគ្រប់គ្រង ការចេញប័ណ្ណសំគាល់ និងកាលបរិច្ឆេទ**

៤.១- គ្រប់ស្ថាប័នកងឯកភាព ត្រូវបំពេញបែបបទស្នើសុំប័ណ្ណសំគាល់យានយន្ត និងផ្លាកលេខចរាចរ តាមសមត្ថកិច្ចជំនាញ និងបានការទទួលស្គាល់របស់មេបញ្ជាការស្ថាប័នកងឯកភាព ឆ្លងតាមឋានានុក្រមមកក្រសួងការពារជាតិ ដើម្បីពិនិត្យផ្តល់ ជូនសំរាប់ប្រើប្រាស់ ។ គំរោងស្នើសុំត្រូវភ្ជាប់មកជាមួយនូវបញ្ជីស្ថិតិ ដូចមានចែងក្នុងប្រការ ៣ ។

៤.២- អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស មានភារៈកិច្ចពិនិត្យលើគំរោងស្នើសុំរបស់បណ្តាស្ថាប័នកងឯកភាព នឹងធ្វើការចេញប័ណ្ណសំគាល់យានយន្ត និងផ្លាកលេខចរាចរ អោយដល់ស្ថាប័នកងឯកភាពសំរាប់យកទៅប្រើប្រាស់ ។

៤.៣- គ្រប់ស្ថាប័នកងឯកភាពក្នុងកងយោធពលខេមរភូមិន្ទ ត្រូវធ្វើបែបបទ ដើម្បីស្នើសុំប័ណ្ណសំគាល់យានយន្ត និងផ្លាកលេខចរាចរថ្មី ដើម្បីបំពាក់អោយយានយន្តរបស់ស្ថាប័នកងឯកភាព ដូចក្នុងប្រការ ១ អោយបានចប់សព្វគ្រប់នូវដំណាច់ខែធ្នូ ឆ្នាំ ២០០៥ យ៉ាងយូរបំផុត ។

៤.៤ - ផ្លាកលេខចរាចរចាស់ ដែលអគ្គបញ្ជាការបានចេញ ត្រូវបញ្ចប់ត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៤ ។

**ប្រការ ៥** : ជនណាប្រើប្រាស់ផ្លាកលេខ ខ.ម ក្លែងក្លាយ និងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ការត្រួតពិនិត្យយានយន្តរបស់កងយោធពលខេមរភូមិន្ទ ជាភារៈកិច្ចតែមួយគត់របស់កងរាជអាវុធហត្ថ ។

**ប្រការ ៦** : ខ្លឹមសារនៃសេចក្តីណែនាំ សេចក្តីកំណត់ទាំងឡាយ ដែលផ្ទុយនិងខ្លឹមសារនៃសេចក្តីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧** : អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គលេខាធិការ ក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស មេបញ្ជាការកងទ័ពជើងគោក មេបញ្ជាការកងទ័ពជើងទឹក មេបញ្ជាការកងទ័ពជើងអាកាស មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គនាយក នាយក ប្រធាន មេបញ្ជាការស្ថាប័នកងឯកភាពចំណុះក្រសួងការពារជាតិនិងអគ្គបញ្ជាការដ្ឋានត្រូវមានវិធានការផ្សព្វផ្សាយ និងអនុវត្តសេចក្តីប្រកាសនេះ អោយបានម៉ឺងម៉ាត់និងមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយឧ.ផ្កាយមាស៥ ទៀ-បាញ់ នាយឧ.ផ្កាយមាស៤.ញឹក-ប៊ុនឆៃ

<u>ផ្ញើជូន</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសាធារណការនិងដឹកជញ្ជូន
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៧

  " ដើម្បីអនុវត្ត "
- ឯកសារ កាលប្បវត្តិ